PLACE
STAMP
HERE

DIVISION OF CHILD SUPPORT
PO BOX 11520
TACOMA WA  98411-5520

### ធនធានច្បាប់

ការអប់រំ ដំបូន្មាន និងការណែនាំ ផ្នែកច្បាប់ដែលសម្របសម្រួលដោយគម្រោងយុត្តិធម៌ភាគពាយព្យ
គម្រោង (CLEAR)
**888-201-1014**
**www.nwjustice.org**

### មជ្ឈមណ្ឌលច្បាប់របស់ស្ត្រីភាគពាយព្យ

ខ្សែទូរស័ព្ទព័ត៌មាន និងការណែនាំ
**206-621-7691**

### គេហទំព័រតុលាការ

ទាក់ទងតុលាការនេះ
**www.courts.wa.gov/**

### ផ្នែកជំនួយកុមារ DCS

PO Box 11520
Tacoma, WA 98411
www.dshs.wa.gov/dcs/
DCS-CRU@dshs.wa.gov

### គ្លីនិកស្របច្បាប់ និងព័ត៌មានស្របច្បាប់

**wsba.org/atj/contact/legasst.htm**

### ព័ត៌មានទាំងអស់ក្នុងកំណត់ត្រា DCS គឺជាការសម្ងាត់

អ្នកអាចមាននរណាម្នាក់ (សាច់ញាតិ មិត្តភក្តិ ឬមេធាវី) ទូរស័ព្ទទៅ DCS តាងនាមឱ្យអ្នក ។ យើងអាចឆ្លើយសំណួរទូទៅសម្រាប់នរណាម្នាក់ ប៉ុន្តែយើងមិនអាចពិភាក្សាព័ត៌មានលម្អិតលើសំណុំរឿងជាក់លាក់បានទេ លុះត្រាតែយើងមានការអនុញ្ញាតជាលាយលក្ខណ៍អក្សររបស់អ្នក ។

**ទូរស័ព្ទទៅ ការិយាល័យ DCS ដែលនៅជិតអ្នកបំផុត ឬទូរស័ព្ទទៅលេខ 800-442-KIDS (5437) ដើម្បីស្វែងរកការិយាល័យដែលដោះស្រាយសំណុំរឿងរបស់អ្នក ។**

### ការិយាល័យ DCS

| | |
|---|---|
| **Everett** | 800-729-7580<br>425-438-4800 |
| **Kennewick** | 800-345-9981<br>509-374-2000 |
| **Olympia** | 800-345-9964<br>360-664-6900 |
| **Seattle** | 800-526-8658<br>206-341-7000 |
| **Spokane** | 800-345-9982<br>509-363-5000 |
| **Tacoma** | 800-345-9976<br>253-597-3700 |
| **Vancouver** | 800-345-9984<br>360-696-6100 |
| **Wenatchee** | 800-535-1113<br>509-886-6800 |
| **Yakima** | 800-441-0859<br>509-249-6000 |
| ទីស្នាក់ការកណ្តាល | 800-457-6202<br>360-664-5000 |

កម្មវិធីជំនួយកុមាររបស់រដ្ឋវ៉ាស៊ីនតោន



# តើខ្ញុំនៅតែត្រូវបង់ថ្លៃជំនួយកុមារទៀតទេបើខ្ញុំជាប់ពន្ធនាគារ?

Washington State Department of Social & Health Services
*Transforming lives*

DSHS 22-423 CA (Rev. 9/16) Cambodian

## តើទំនួលខុសត្រូវលើជំនួយកុមាររបស់ខ្ញុំបាត់បង់ដែរទេខណៈពេលខ្ញុំជាប់ពន្ធនាគារ?

ទេ ។ ការទូទាត់លើជំនួយកុមាររបស់អ្នកគឺដល់ជារៀងរាល់ខែ ទោះបីជាអ្នកនៅក្នុងពន្ធនាគារក៏ដោយ ។

ប្រសិនបើអ្នកមិនអាចបង់ បំណុលជំនួយរបស់អ្នកបន្តកាន់តែធំឡើងៗជារៀងរាល់ខែ លុះត្រាតែអ្នកផ្លាស់ប្តូរការបង្គាប់បញ្ជា ។

## តើមានអ្វីកើតឡើងទៅលើ 20% ដែលកាត់ចេញពីប្រាក់ដែលចូលក្នុងគណនីអ្នកទោសរបស់ខ្ញុំ?

ច្បាប់រដ្ឋវ៉ាស៊ីនតោនតម្រូវឱ្យ ក្រសួងអប់រំកែប្រែ (DOC) យកប្រាក់សម្រាប់ជំនួយកុមារពីចំណូល ប្រាក់ឧបត្ថម្ភ និងអត្ថប្រយោជន៍ទូទាត់សំណងលើបុគ្គលិកដែលបានបង់ឱ្យអ្នក ។ ប្រាក់ដែលពួកគេយកគឺត្រូវបានម្តងក្នុងមួយខែទៅ ផ្នែកជំនួយកុមារ (DCS) ដើម្បីអនុវត្តលើសំណុំរឿងជំនួយកុមាររបស់អ្នក ។ បើយើងទទួលច្រើនជាងអ្នកជំពាក់ ប្រាក់បន្ថែមនឹងត្រូវបានបង្វិលត្រលប់ទៅគណនីអ្នកទោសរបស់អ្នកវិញ ។

## តើខ្ញុំអាចធ្វើអ្វីខ្លះ?

ដោយការបំពេញទម្រង់បែបបទក្នុងកូនសៀវភៅនេះ ហើយផ្ញើវាត្រលប់មកយើង អ្នកអាចស្នើ DCS ឱ្យ៖

- ពិនិត្យឡើងវិញនូវការបង្គាប់បញ្ជាលើជំនួយកុមាររបស់អ្នកដើម្បីបន្ទាបការទូទាត់ជំនួយបច្ចុប្បន្ន ។ នេះអាចកែប្រែការបង្គាប់បញ្ជារបស់អ្នកបាន ។ ប្រសិនបើអ្នកមិនមានសំណុំរឿងជាមួយ DCS ទេ អ្នកអាចដាក់ពាក្យសុំសេវាកម្មផ្សេងៗរបស់យើង ។
- បន្ទាប ឬដកចេញចំណែកនៃបំណុលជំនួយកុមាររបស់អ្នកដែលអ្នកជំពាក់រដ្ឋវ៉ាស៊ីនតោន ។ ដំណើរការនេះត្រូវបានហៅថា ក្រុមប្រឹក្សាសន្និសីទ ។
- ផ្ញើឱ្យអ្នកនូវពាក្យសុំសម្រាប់សេវាកម្មផ្សេងៗ ។ យើងបង្កើតបិតុភាព និងបង្កើត កែប្រែ និងដាក់ឱ្យអនុវត្តនូវការបង្គាប់បញ្ជាសម្រាប់ជំនួយកុមារ និងការធានារ៉ាប់រងសុខភាព ។
- បញ្ចេញការកាប់កាន់របស់យើងលើប័ណ្ណបើកបររបស់អ្នក ។

DCS មិនផ្តល់សេវាផែនការស្ួរសុខទុក្ខ មើលថែរក្សា ឬសេវាឪពុកម្តាយឡើយ ។

## តើការផ្លាស់ប្តូរ (ការកែប្រែ) ការបង្គាប់បញ្ជារបស់ខ្ញុំអាចជួយខ្ញុំដោយរបៀបណា?

ជំនួយកុមារគួរតែត្រូវបានកំណត់ដើម្បីឆ្លុះបញ្ចាំងពីស្ថានភាពបច្ចុប្បន្នរបស់អ្នក ។ ប្រសិនបើអ្នកចង់ផ្លាស់ប្តូរចំនួនទឹកប្រាក់ដែលអ្នកត្រូវបានទូទាត់សម្រាប់ជំនួយបច្ចុប្បន្ន អ្នកត្រូវតែកែប្រែការបង្គាប់បញ្ជាជំនួយកុមាររបស់អ្នក ។

- ការផ្លាស់ប្តូរជំនួយបច្ចុប្បន្នរបស់អ្នកនឹងមិនផ្លាស់ប្តូរចំនួនបំណុលប៉ុណ្ណាដែលអ្នកជំពាក់រួចហើយឡើយ ។
- វាមិនកើតឡើងដោយស្វ័យប្រវត្តិឡើយ អ្នកត្រូវតែបំពេញក្រដាសស្នាម ហើយស្នើសុំផ្លាស់ប្តូរវា ។ វាអាចចំណាយពេលរាប់ខែដើម្បីកែប្រែការបង្គាប់បញ្ជាមួយ ហើយអ្នកត្រូវតែធ្វើការជាមួយយើងគ្រប់ពេលដើម្បីធ្វើឱ្យវាកើតឡើង ។
- ការបង្គាប់បញ្ជាថ្មីកំណត់កាលបរិច្ឆេទចាប់ផ្តើមនៃការផ្លាស់ប្តូរ ។ កាលបរិច្ឆេទចាប់ផ្តើមមិនអាចជាកាលបរិច្ឆេទមុនពេលអ្នកធ្វើការស្នើសុំទៅ DCS ឡើយ ហើយអាចជាពេលក្រោយ ។ អ្នកគួរតែធ្វើការស្នើសុំរបស់អ្នកឱ្យកាន់តែឆាប់តាមតែអាចធ្វើទៅបាន ។

## តើខ្ញុំអាចផ្លាស់ប្តូរចំនួនទឹកប្រាក់ដែលខ្ញុំជំពាក់រួចហើយដោយរបៀបណា?

ពេលខ្លះ ដោយផ្អែកលើកាលៈទេសៈសរុបរបស់អ្នក DCS នឹងពិចារណាលើកលែងបំណុលជំនួយកុមារខ្លះ ឬទាំងអស់ ដែលជំពាក់រដ្ឋវ៉ាស៊ីនតោន ។ នេះកើតឡើងអំឡុងពេលដំណើរការដែលហៅថា ក្រុមប្រឹក្សាសន្និសីទ ។

អង្គភាពក្រុមប្រឹក្សាសន្និសីទមិនអាចលើកលែងបំណុងដែលជំពាក់ដោយផ្ទាល់ទៅនរណាម្នាក់ផ្សេង ឬរដ្ឋផ្សេង ។ ទោះបីជាយ៉ាងណា បុគ្គលដែលជំពាក់បំណុលជំនួយកុមារអាចលើកលែងបំណុលដែលអ្នកជំពាក់ពួកគេបាន។ ប្រសិនបើនោះជាអ្វីដែលពួកគេចង់ធ្វើ ពួកគេត្រូវតែទាក់ទង DCS សម្រាប់ព័ត៌មានបន្ថែម ។

## តើដូចម្តេច បើខ្ញុំទទួលបានសេចក្តីជូនដំណឹងថ្មីមួយ?

DCS អាចបម្រើជូនអ្នកនូវសេចក្តីជូនដំណឹងស្របច្បាប់ ខណៈពេលអ្នកនៅជាប់ពន្ធនាគារ ដែលរួមទាំងសេចក្តីជូនដំណឹងក្នុងការបង្កើតជំនួយកុមារ ។

## មិនត្រូវមិនអើពើសំបុត្រពី DCS ឡើយ !

ជាធម្មតា អ្នកមានពេល 20 ថ្ងៃក្នុងការឆ្លើយសេចក្តជូនដំណឹងស្របច្បាប់ដែលយើងផ្ញើទៅអ្នក ។ (សេចក្តីជូនដំណឹងនីមួយៗមានព័ត៌មានអំពីសិទ្ធិរបស់អ្នក ។)

- ប្រសិនបើអ្នកបដិសេធលក្ខខណ្ឌនៅក្នុងសេចក្តីជូនដំណឹងនេះ អ្នកអាចស្នើសុំយើងសម្រាប់បញ្ចេញ ។
- ប្រសិនបើអ្នកមិនឆ្លើយតបសេចក្តីជូនដំណឹងនេះ វានឹងក្លាយជាស្ថាពរដោយស្វ័យប្រវត្តិបន្ទាប់ពីហួសរយៈពេល 20 ថ្ងៃ ហើយយើងនឹងចាប់ផ្តើមដាក់ឱ្យអនុវត្តវា ។

## ចុះចំណែកប័ណ្ណបើកបររបស់ខ្ញុំ?

ឱ្យយើងដឹងនៅពេលអ្នកនៅក្នុងពន្ធនាគារ ឬដោះលែងឱ្យធ្វើការ ហើយយើងនឹងបញ្ចេញការកាន់កាប់ប័ណ្ណបើកបររបស់អ្នក និងរក្សាវាទុករហូតដល់ 30 ថ្ងៃ បន្ទាប់ពីអ្នកត្រូវបានដោះលែង ។

អំឡុងពេល 30 ថ្ងៃនោះ អ្នកត្រូវការទាក់ទងមកយើងម្តងទៀតដើម្បីដោះស្រាយលើផែនការទូទាត់ ។ ប្រសិនបើអ្នកមិនទាក់ទងទេ ប័ណ្ណបើកបររបស់អ្នកអាចត្រូវបានពន្យារម្តងទៀតដោយជំនួយកុមារ ។ អ្នកទូរស័ព្ទមក DCS កាន់តែឆាប់ វានឹងកាន់តែងាយស្រួលសម្រាប់យើងក្នុងការធ្វើការជាមួយអ្នក ។ យើងត្រូវបានតម្រូវឱ្យប្រមូលជំនួយកុមាររបស់អ្នក និងអ្វីមួយឆ្ពោះទៅកាន់បំណុលជំនួយទាំងឡាយ ។

## តើអ្វីខ្លះនឹងកើតឡើង នៅពេលខ្ញុំរកបានការងារធ្វើ?

នៅពេលអ្នកមានកាតព្វកិច្ចលើជំនួយកុមារដែលអ្នកត្រូវបានតម្រូវឱ្យជូនដំណឹងមកយើងរាល់ពេលដែលអ្នកទទួលការងារថ្មីមួយ ។ ប្រសិនបើទាក់ទងមកយើង នៅពេលអ្នករកបានការងារ យើងអាចធ្វើការជាមួយអ្នកលើចំនួនទឹកប្រាក់ដែលអ្នកទូទាត់រាល់ខែឆ្ពោះទៅកាន់បំណុលរបស់អ្នក ។

ប្រសិនបើអ្នកមិនជូនដំណឹងផ្នែកជំនួយកុមារទេ នោះនៅពេលយើងផ្ញើចេញនូវបណ្តឹងរឹបទ្រព្យពីតតិយជនទៅកាន់និយោជករបស់អ្នក វាអាចមានរហូតដល់ពាក់កណ្តាលនៃសែកបង់ប្រាក់របស់អ្នក ។

### ជូរស័ព្ទមក DCS នោះយើងនឹងធ្វើការជាមួយអ្នក !

ស្កុតបានបិទត្រង់នេះ មុនពេលផ្ញើសំបុត្រប្រៃសណីយ

# ការស្នើសុំព័ត៌មាន DCS

**សូមផ្ញើមកខ្ញុំនូវទម្រង់បែបបទដើម្បី ៖**

- ☐ ស្នើ DCS ឱ្យផ្លាស់ប្តូរការបង្គាប់បញ្ជាជំនួយកុមាររបស់ខ្ញុំ ។
- ☐ ដាក់ពាក្យសុំសេវាអនុវត្តន៍ពេញលេញពី DCS ។
- ☐ ស្នើសុំក្រុមប្រឹក្សាសន្និសីទ ។
- ☐ អនុញ្ញាតឱ្យនរណាម្នាក់ផ្សេងនិយាយអំពីសំណុំរឿងរបស់ខ្ញុំជាមួយ DCS ។
- ☐ ខ្ញុំជាប់ពន្ធនាគារ សូមបញ្ចេញប័ណ្ណបើកបររបស់ខ្ញុំ ។
- ☐ ខ្ញុំមានពិការភាព និងត្រូវការជំនួយពិសេស ។
- ☐ ខ្ញុំអានភាសាអង់គ្លេសមានកម្រិត ។ សូមផ្ញើទម្រង់បែបបទជា ភាសា ________

ផ្សេងៗ (ពន្យល់) ________

ខ្ញុំជាប់ពន្ធនាគារនៅ ________ លេខ DOC របស់ខ្ញុំគឺ ________ កាលបរិច្ឆេទដោះលែងរបស់ខ្ញុំដែលប៉ាន់ស្មានគឺ ________ លេខសំណុំរឿង DCS ________

ឈ្មោះ ________

អាសយដ្ឋាន (ផ្លូវ ឬប្រអប់សំបុត្រ) ________

ទីក្រុង ________ រដ្ឋ ________ ហ្ស៊ីបកូដ ________

ហត្ថលេខា ________ កាលបរិច្ឆេទ ខខ / ថថ / ឆឆ